**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥១ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់អនុវត្ត គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់អនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ ដែលសរសេរជាអក្សរកាត់ថា គ.អ.គ.អ.ច.ក. ដើម្បីដឹកនាំនិងសម្របសម្រួលដំណើរការធ្វើមូលដ្ឋាននីយកម្ម និងអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ ក្នុងបរិការណ៍កម្ពុជា ឈានទៅសម្រេចឱ្យបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិនៅឆ្នាំ២០៣០។

**ប្រការ២ ._**

គ.អ.គ.អ.ច.ក. មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ប៊ិន ត្រឈៃ** | រដ្ឋមន្ត្រីក្រសួងផែនការ | ប្រធាន |
| ២- ឯកឧត្តម **ទួន ថាវរៈ** | រដ្ឋលេខាធិការប្រចាំការក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម **ឈាង វណ្ណារិទ្ធ** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤- ឯកឧត្តម **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- ឯកឧត្តម **ឈា ប៊ុនរិទ្ធ** | រដ្ឋលេខាធិការប្រចាំការក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ៦- លោកជំទាវ **ភុយ សុជានី** | រដ្ឋលេខាធិការប្រចាំការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិកា |
| ៧- ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ | សមាជិក |
| ៨- ឯកឧត្តម **អ៊ុំ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តម **ភាន់ ផារិទ្ធ** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការ អន្តរជាតិ | សមាជិក |
| ១០- ឯកឧត្តម **រស់ សុវែន** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១- ឯកឧត្តម **ផូ ផារិទ្ធ** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២- ឯកឧត្តម **ប៉ែន សុវិជាតិ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣- ឯកឧត្តម **ភាន ច័ន្ទមេត្តា** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៤- ឯកឧត្តម **ប៊ុន ណារិទ្ធ** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១៥- ឯកឧត្តម **អ៊ុំ បូរាត** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៦- ឯកឧត្តម **អុល រ៉ូ** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៧- ឯកឧត្តម **រស់ សាលីន** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៨- ឯកឧត្តម **ជួប ប៉ារីស** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៩- ឯកឧត្តម **អ៊ុក សំរេច** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ២០- ឯកឧត្តម **ជិន ម៉ាលីន** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ២១- លោកជំទាវ **វី ស្រីពៅ** | រដ្ឋលេខាធិការក្រសួងអធិការកិច្ច | សមាជិកា |
| ២២- ឯកឧត្តម **ជុន វ៉ាត** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ២៣- ឯកឧត្តម **ឡូ វាសនាគីរី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២៤- ឯកឧត្តម **ឡុង ប៉ុណ្ណាស៊ីវត្ថ** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ២៥- ឯកឧត្តម **ផាន់ ចន្ទតារា** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ២៦- លោកជំទាវ **ច័ន្ទ សុរិយ៍** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ២៧- ឯកឧត្តម **ហួត ស៊ីនាដ** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

២៨- ឯកឧត្តម **ម៉ុល ពីឌូ** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ សមាជិក

២៩- ឯកឧត្តម **ម៉ុន នី** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

៣០- ឯកឧត្តម **ស៊ុម សុខម្ភ** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន សមាជិក

៣១- ឯកឧត្តម **កេត សោផាន់** សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

៣២- ឯកឧត្តម **ទុយ ស៊ីនណា** រដ្ឋលេខាធិការក្រសួងផែនការ សមាជិក

៣៣- ឯកឧត្តម **ប៉ាន សុបណ្ណិត** រដ្ឋលេខាធិការក្រសួងផែនការ សមាជិក

៣៤- ឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ុក កោសា** អនុរដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៣៥- ឯកឧត្តម **ឃឹម លាត** ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា សមាជិក

៣៦- ឯកឧត្តម **សឹង រេត** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក

៣៧- ឯកឧត្តម **សុខ ស៊ីឡូ** អគ្គលេខាធិការនៃក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យ
កសិកម្ម និងជនបទ សមាជិក

៣៨- ឯកឧត្តម **គាំ រីមួន** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអេស្កាប់ សមាជិក

៣៩- ឯកឧត្តម **ភាន់ ឬទ្ធី** អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិជំរុញចលនា
ភូមិមួយផលិតផលមួយ សមាជិក

៤០- ឯកឧត្តម **គឹម ឧឌ្ឍនា** អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិគ្រប់គ្រង
គ្រោះមហន្តរាយ សមាជិក

៤១- ឯកឧត្តម **រស់ សីលវ៉ាត់** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សមាជិក

៤២- ឯកឧត្តម **តន់ សារ៉ា** អគ្គលេខាធិការរងនៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាព
កំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន សមាជិក

៤៣- ឯកឧត្តម **ទូច ស៊ុនណារី** អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ សមាជិក

៤៤- ឯកឧត្តម **អ៊ឹម សួរ** អគ្គលេខាធិការរងនៃគណៈកម្មាធិការសហប្រតិបត្តិការ
អភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៤៥- ឯកឧត្តម **ហឿន សំនៀង** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា
អភិវឌ្ឍន៍កម្ពុជា សមាជិក

៤៦- ឯកឧត្តម **ហ៊ែល តូនី** អនុប្រធានក្លាប់រួមនៃអាជ្ញាធរទន្លេសាប សមាជិក

៤៧- ឯកឧត្តម **ទេព ចាន់អុនឧបធីភេក្ស** អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុនៃ
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សមាជិក

៤៨- ឯកឧត្តម **លឹម ប៊ុនហុក** អគ្គលេខាធិការរងរដ្ឋសភា សមាជិក

៤៩- ឧកញ៉ា **ខួន ម៉េងតិច** អគ្គនាយកសភាពាណិជ្ជកម្មកម្ពុជា សមាជិក

៥០- ឯកឧត្តម **ថេង បញ្ញាធន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកផែនការ
នៃក្រសួងផែនការ សមាជិក

៥១- លោក **សុត និមល** ប្រធានការិយាល័យសម្របសម្រួលអង្គការ
សហប្រជាជាតិប្រចាំកម្ពុជា សមាជិក

៥២- លោក **សុខ សុភក្តិ** នាយករងប្រតិបត្តិនៃវិទ្យាស្ថានបណ្ដុះបណ្ដាលនិង
ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា សមាជិក

៥៣- លោក **សឿន សារឿន** នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សមាជិក

៥៤- លោកស្រី **ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិនៃអង្គការគណៈកម្មាធិការ សហប្រតិបត្តិការដើម្បីកម្ពុជា សមាជិកា

៥៥- តំណាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ១រូប សមាជិក។

គ.អ.គ.អ.ច.ក. អាចមានសមាសភាពបន្ថែមជាអនុប្រធានឬសមាជិក ដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។ សមាសភាពបន្ថែមនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ៣ ._**

គ.អ.គ.អ.ច.ក. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំនិងសម្របសម្រួលប្រមូលធាតុចូលសម្រាប់រៀបចំឬកែសម្រួលគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
- ដឹកនាំ សម្របសម្រួល និងរៀបចំកិច្ចប្រជុំនិងសិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន វិស័យឯកជន និងដៃគូអភិវឌ្ឍនានា ដើម្បីប្រមូលធាតុចូលតាមការចាំបាច់
- ផ្តួចផ្តើមនិងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាលពីបញ្ហាប្រឈមនិងដំណោះស្រាយនានាដែលទាក់ទងនឹងគោលដៅនានាតាមវិស័យនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
- ពិនិត្យនិងសម្រេចជាគោលការណ៍កម្រិតអន្តរក្រសួងលើសេចក្តីព្រាងចុងក្រោយនៃឯកសារឬឯកសារកែសម្រួលនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា មុននឹងដាក់ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីតាមរយៈយន្តការទីស្តីការគណៈរដ្ឋមន្ត្រី
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា រួមទាំងរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី និងជូនអង្គការសហប្រជាជាតិ តាមរយៈវេទិកានយោបាយកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៤ ._**

អនុប្រធាននិងសមាជិក គ.អ.គ.អ.ច.ក. ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន គ.អ.គ.អ.ច.ក.។ ក្នុងករណីប្រធានអវត្តមានឬករណីចាំបាច់ ប្រធាន គ.អ.គ.អ.ច.ក. អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៥ ._**

គ.អ.គ.អ.ច.ក. មានសិទ្ធិអញ្ជើញប្រធានស្ថាប័នឬតំណាង ឥស្សរជន ឬអាជ្ញាធរមូលដ្ឋានចូលរួមប្រជុំតាមការចាំបាច់។

គ.អ.គ.អ.ច.ក. អាចអញ្ជើញដៃគូអភិវឌ្ឍ វិស័យឯកជន ទីប្រឹក្សា ឬជំនាញការជាតិនិងអន្តរជាតិ ចូលរួមប្រជុំពិគ្រោះយោបល់តាមការចាំបាច់។

**ប្រការ៦ .-**

គ.អ.គ.អ.ច.ក. អាចបង្កើតក្រុមការងារតាមការចាំបាច់ ដែលកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.អ.គ.អ.ច.ក.។

**ប្រការ៧ .-**

គ.អ.គ.អ.ច.ក. មានលេខាធិការដ្ឋានមួយជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃ គ.អ.គ.អ.ច.ក. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងផែនការនិងជាប្រធាន គ.អ.គ.អ.ច.ក.។

**ប្រការ៨ .-**

គ.អ.គ.អ.ច.ក. មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងផែនការ ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៥ រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ